# ប្រាសាទកោះកេរ



# ប្រាសាទកោះកេរ



រៀបរៀងដោយអ្នកស្រី កែវ ណារុំ
វិចិត្ររូបភាពដោយ លោក ហ៊ុំ ចិន្តា
បោះពុម្ពផ្សាយដោយអង្គការសន្តិស្រីត្រចិត្ត



កោះកេរជារាជធានីដ៏សំខាន់មួយ នាសម័យចក្រភពអង្គរនៅចន្លោះឆ្នាំ៩២១-៩៤៤ ដោយព្រះបាទជ័យវរ្ម័នទី៤ បានគ្រងរាជនៅទីនោះពីឆ្នាំ៩២៨-៩៤១ ។ រាជធានីនេះ មានចម្ងាយប្រមាណជា ១៤០ គីឡូម៉ែត្រ នាភាគឦសាននៃទីក្រុងយសោធរបុរៈ (រាជធានីអង្គរ) ។

បច្ចុប្បន្នអតីតរាជធានីនេះ ស្ថិតនៅក្នុងភូមិកោះកេរ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ។ ព្រះបាទជ័យវរ្ម័នទី ៤ បានកសាងប្រាសាទធំតូចជាច្រើននៅតំបន់នេះ ដូចជាប្រាសាទប្រាង្គ ប្រាសាទក្រហម ប្រាសាទលិង្គ ប្រាសាទក្រចាប់ ប្រាសាទបន្ទាយពីរជាន់ ប្រាសាទដំរី ប្រាសាទប្រាំ ប្រាសាទនាងខ្មៅ ។



ក្នុងចំណោមប្រាសាទទាំងអស់នោះ ប្រាសាទប្រាង្គធំជាងគេ ។ ដូចនេះគេនាំគ្នាហៅថា **ប្រាសាទធំ** ។ តែក៏មានអ្នកខ្លះហៅថា ប្រាសាទកំពែងដោយសារមានកំពែងធំវែងព័ទ្ធជុំវិញ ។ យើងនិយមហៅថា "**ប្រាសាទកោះកេរ**" គឺជាកោះនៃកិត្តិយស ឬកេរឈ្មោះ ។ ប្រាសាទកោះកេរមានទម្រង់ជាពីរ៉ាមីត ឬជាសោជីជ្រុងដែលមានលក្ខណៈប្លែកខុសពីប្រាសាទមុនៗ ទាំងឡាយដែលកសាងឡើងដោយបុព្វបុរសខ្មែរ ។



ប្រាសាទនេះមានកំពស់រហូតដល់ ៣៥ម៉ែត្រ ជាប្រាសាទមួយខ្ពស់ បន្ទាប់ពីប្រាសាទអង្គរវត្ត ។ ប្រាសាទធំ ឬប្រាសាទប្រាង្គជាប្រាសាទភ្នំ និងជាទំរទ្រលិង្គទេវរាជដ៏ធំមួយដែលមានកំពស់១៨ម៉ែត្រ និងអង្កត់ផ្ចិតប្រវែង ៩ម៉ែត្រ (សាងពីលោហធាតុ ឬស្រោបលោហធាតុ) ។ ប៉ុន្តែត្រូវបានគេគាស់រំលើង ហើយបច្ចុប្បន្ននេះ យើងមិនបានដឹងឡើយ ។





យោងតាមហេតុការណ៍ ស្ថានភាពភូមិសាស្ត្រ និងលក្ខណៈនៃសម្បត្តិប្រាសាទកោះកេរ បុរាណាចារ្យខ្មែរបានប្រឌិតរឿងព្រេងនិទានមួយគឺរឿង **ស្ដេចដំរីស** ដែលមានសេចក្ដីដូចតទៅ :



នាសម័យកាលមួយ ស្រុកកើតគ្រោះទុរ្ភិក្សអត់ឃ្លានដោយសារអាកាសធាតុក្តៅហួតហែងគ្មានភ្លៀងសោះ ។ អ្នកស្រុកបាននាំគ្នាចូលទៅព្រៃដើម្បីរកជីកក្តួចដំឡូងព្រៃយកមកបរិភោគ ។





ក្នុងចំណោមនោះ មាននារីក្រមុំព្រហ្មចារិនីម្នាក់ជាកូនកំព្រាបានដើរចេញពីពួកអ្នកស្រុកដើម្បីទៅរកទឹកផឹក ។ នៅពេលដើរឃ្លាតឆ្ងាយពីគេបន្តិច នាងក៏ប្រទះឃើញដំរីសមួយពីចម្ងាយ ។ ដំរីនោះបានទុកដានជើងថ្មីៗជាច្រើននៅតាមផ្លូវ ។

លុះដើរទៅមុខបានបន្តិច នាងបានឃើញទឹកដក់នៅក្នុងដានជើងដំរីនោះ ។ នាងត្រេកអរណាស់ ក៏លុតជង្គង់ឱនក្បង់ទឹកនោះមកផឹក ហើយមានអារម្មណ៍ថាជាទឹកនោមដំរី ។







ក្រោយពេលវិលត្រឡប់មកផ្ទះវិញ នាងក៏ចាប់មានផ្ទៃពោះ ។ ពេលឃើញនាងមានផ្ទៃពោះដោយគ្មានប្ដីដូច្នេះ អ្នកស្រុកយល់ថាអាចនឹងកើតមានគ្រោះចង្រៃដល់ស្រុកភូមិ ។ ដូច្នេះពួកគេបាននាំគ្នាបណ្ដេញនាងចេញពីភូមិ ។





ក្រោយមកនាងក៏សំរាលបានកូនស្រីម្នាក់មានរូបឆោមល្អណាស់ ។ ពេលធំពេញជំទង់ កូនស្រីនោះតែងចេញពីព្រៃទៅលេងជាមួយកូនអ្នកស្រុក ។ តែគួរឱ្យអាណិតនាងណាស់ ព្រោះក្មេងៗទាំងនោះតែងតែតិះដៀលនាងថា "កូនអត់ឪ" ។



កូនស្រីនោះតែងយំ ហើយរត់មកប្រាប់ម្ដាយពីពាក្យតិះដៀលរបស់គេ ព្រមទាំងសួររកឪពុក ប៉ុន្តែម្ដាយនាងគ្មានពាក្យអ្វីនឹងប្រាប់ឡើយ ។ លុះក្រោយមកម្ដាយនាងមានជំងឺជាទំងន់ ។ គាត់បាននិយាយប្រាប់ដំណើររឿងឱ្យកូនបានដឹង ។





ដោយជំងឺធ្ងន់ពេក គាត់ក៏ទទួលមរណភាពទៅ ។ ក្រោយពេលរៀបចំទុកដាក់សពម្ដាយស្រួលបួលហើយ ក្មេងស្រីនោះក៏បានដើររំពៃរកសត្វដំរីសតាមបណ្ដាំម្ដាយ ។ នាងដើរត្រាច់ចរគ្រប់ទិសទី ក៏បានប្រទះនឹងពួកមនុស្សកំពុងរត់គេចពីស្ដេចដំរីសដែលដេញព្រេច ។



ផ្ទុយទៅវិញក្មេងស្រីនោះរត់សំដៅទៅរកស្តេចដំរីស ។ ដោយហេតុតែនិស្ស័យជាឪពុក និងកូន ស្តេចដំរីសក៏កើតមានចិត្តអាណិតស្រលាញ់លើកត្រកងនាងដាក់លើខ្នងយកទៅចិញ្ចឹមបីបាច់រក្សាដោយដាក់ឈ្មោះថា "ស្រទនំសារស្ត្រា" ។



ពេលពេញវ័យគ្រប់ នាងស្រទន់សាស្ត្រាមានរូបឆោមល្អពន់ពេកធ្វើឱ្យស្ដេចដំរីសមានការព្រួយបារម្ភពីកូនយ៉ាងខ្លាំង ។ គិតពិចារណាសព្វគ្រប់ ស្ដេចដំរីសក៏រៀបចំសង់ប្រាសាទសសរមួយឱ្យកូនស្រីស្នាក់នៅ ។ ដោយមិនចង់ឱ្យកូនស្រីចុះពីប្រាសាទ ស្ដេចដំរីសតែងតែទំនុកបំរុងកូនមិនឱ្យខ្វះខាតឡើយ ។



កាយវិការរបស់ស្តេចដំរីសគួរឱ្យចាប់អារម្មណ៍ គឺការសម្តែងសក់ ។ រាល់ពេលមកដល់ប្រាសាទ ស្តេចដំរីសតែងតែពោលពាក្យយ៉ាងពីរោះថា "ស្រទន់សាស្ត្រា ទម្លាក់សក់មកវ៉ា បិតាមកហើយ សៀតផ្កាខាងមុខ សិតសក់ខាងក្រោយ បិតារបាំឱ្យ ស្រទន់សាស្ត្រា" ។



ពាក្យពេចន៍ដ៏ពីរោះនេះ បានឮទៅដល់ព្រានព្រៃម្នាក់ ។ ព្រានព្រៃនោះក៏បាននាំរឿងនេះទៅក្រាបទូលព្រះអង្គម្ចាស់មួយអង្គ ។ ពេលបានទទួលដំណឹងហើយ ព្រះអង្គក៏យាងមកប្រពាតព្រៃ ហើយបានមកលបពួនមើលឃើញនាងស្រទន់សាស្ត្រា មានរូបល្អពន់ពេក ក៏ចាប់ចិត្តស្រឡាញ់ ។





ព្រះអង្គម្ចាស់ទន្ទេញកំណាព្យនោះ ហើយឆ្លៀតឱកាសស្ដេចជីវសមិននៅក៏ពោលត្រាប់តាម ។ នាងស្រទន់សាស្ត្រាឮកំនោលនោះ ស្មានថាឪពុកមក ក៏ទម្លាក់សក់ចុះ ។ ឱកាសល្អហុចឱ្យ ព្រះអង្គម្ចាស់នោះក៏សំកាលខ្លួនឡើងតាមសក់របស់នាង រហូតដល់ខាងលើប្រាសាទ ហើយល្បួងលោមសុំស្នេហ៍ពីនាង រួចហើយក៏នាំនាងយកទៅទុកឯប្រាសាទរបស់ព្រះអង្គ ។

ថ្ងៃងពីស្តេចដំរីស អស់រយៈពេលបីថ្ងៃកន្លងមកហើយ បានដើររកផ្លែឈើ និងផ្កាក្រអូបគ្រប់ប្រភេទដើម្បីយកទៅផ្គត់ផ្គង់បុត្រីបណ្តូលចិត្តតែមួយ ។ លុះរកបាន គ្រប់គ្រាន់ហើយ ស្តេចដំរីសក៏ធ្វើដំណើរដោយលេះលោំងទៅរកកូន ។ ពេលទៅ ដល់ប្រាសាទ ស្តេចដំរីសក៏បន្លឺសម្លីដូចសព្វដង ។ ប៉ុន្តែ ស្ងាត់ឈឹងមិនឃើញកូន ទម្លាក់សក់មកសោះ ។





ដោយគិតថា  កូនប្រហែលជាដេកលក់ ស្តេចដំរីសក៏បន្លឺសម្លេងជំរែលៗម្តងហើយម្តងទៀត កាន់តែខ្លាំងឡើងៗ។ នៅតែមិនឃើញកូន ក៏មានក្តីបារម្ភកាន់តែខ្លាំង ។ ស្តេចដំរីសក៏ចេញដំណើរយ៉ាងតក់ក្រហល់ដោយស្វែងរកកូនយ៉ាងវក់វីពីប្រាសាទមួយទៅប្រាសាទមួយ  ហើយស្រែកហៅកូនរំពងពេញព្រៃ ព្រមទាំងកាច់កំពូលប្រាសាទនីមួយៗដើម្បីអើតរកមើលកូន ។

បន្ទាប់មក ស្តេចជីវិសបានមកដល់ព្រះរាជដំណាក់របស់ព្រះអង្គម្ចាស់ ដែលបាននាំនាងស្រទន់សាស្ត្រាមកលោក ។ នាងស្រទន់សាស្ត្រា និងព្រះអង្គម្ចាស់ កាលបើបានឮសម្លេងឪពុកស្រែកហៅ ក៏ស្ទុះចេញមកលុតជង្គង់ថ្វាយបង្គំ ព្រមទាំងពោលថា " ទូលព្រះបង្គំសូមថ្វាយបង្គំព្រះបិតា សូមព្រះបិតាមេត្តាប្រោសប្រទានទោសដល់បុត្រទាំងពីរផង "។





ស្តេចដំរីសមានអារម្មណ៍តក់ស្លុតស្រយុតស្រយង់កាយ រហូតដល់ដួលក្រាបចុះ ទាំងបង្ហូរទឹកភ្នែករហាម ហើយពោលដោយចិត្តអួលណែនៈ "ស្រទន់សារស្តា កូនសំលាញ់បិតា កូនធ្វើអំពើខុសឆ្គងនឹងគន្លងប្រពៃណីហើយ បិតាខ្មាសអស់ញាតិសន្តាន ព្រួយនឹងអនាគតរបស់កូន ។ ចូរកូនយកផ្លែឈើ បំពង់ទឹក និងផ្កាពីបិតាជាលើកចុងក្រោយ ។ ចូរកូនទាំងពីរចេះថែរក្សាគ្នាឱ្យបានសុខបិតាលាហើយ!" ។

ដោយក្ដីអាម៉ាស់ និងការខកចិត្តខ្លាំងពេកបណ្ដាលឱ្យស្ដេចដំរីសដួលស្លាប់ភ្លាមមួយរំពេចនៅខាងក្រោយប្រាសាទនោះ ។ បច្ចុប្បន្ននេះ នៅពេលយើងទៅទស្សនាប្រាសាទកោះកេរ្ដិ៍ គួរឆៀងដើរទៅក្រោយប្រាសាទធំដើម្បីពិនិត្យមើលទីទួលមួយដែលចាស់បុរាណបានលើកជានិមិត្តរូបស្ដេចដំរីស ។





សព្វថ្ងៃ មានដើមឈើដុះជាច្រើនរាងដូចដំរីស្រុតបែរក្បាលទៅទិសខាងត្បូង ។ ម្យ៉ាងទៀត អ្នកស្រុកបានយកទង់ក្រពើមកដោតនៅក្បែរជើងភ្នំប៉ែកខាងជើងដើម្បីជានិមិត្តរូបនៃមរណភាពរបស់ស្ដេចដំរីស ។/

ៜៜៜ ចប់ ៜៜៜ